**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# របាយការណ៍កិច្ចប្រជុំ
# ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី៤

១. **ថ្ងៃ ខែ ឆ្នាំ៖** ថ្ងៃសុក្រ ៨កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣

២. **ទីកន្លែង៖** នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាញ(Zoom)

៣. ប្រធាន និងសមាសភាពចូលរួម ៖

៣.១ ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

៣.២ សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការពាក់ព័ន្ធ ដែលចូលរួមផ្ទាល់ចំនួន២៤រូប និងតាមប្រព័ន្ធអនឡាយចំនួន៣២រូប សរុបចំនួន៥៦រូប។

៤. របៀបវារៈ៖

៤.១- មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំដោយ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

៤.២- បទបង្ហាញស្តីពី លទ្ធផលនៃការប៉ាន់ប្រមាណស្ថានភាពមេរោគអេដស៍ ជំងឺអេដស៍ នៅកម្ពុជា ឆ្នាំ២០២៣ ដោយលោកវេជ្ជ. សំរិត សុវណ្ណារិទ្ធ អនុប្រធាន មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ។

៤.៣- មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៥. លទ្ធផល ៖

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស បានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៤ ឆ្នាំ២០២៣ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ដំណើរការនៃកិច្ចប្រជុំមាន៖

**៥.១ ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការ បានមានប្រសាសន៍ជូនអង្គប្រជុំឱ្យបានជ្រាបថា កិច្ចប្រជុំថ្ងៃនេះផ្តោតសំខាន់លទ្ធផលនៃការប៉ាន់ប្រមាណស្ថានភាពមេរោគអេដស៍ ជំងឺអេដស៍ នៅកម្ពុជា ឆ្នាំ២០២៣ ។ ប្រធានបទនៃការពិភាក្សានេះ គឺក្នុងគោលបំណងពិនិត្យនូវលទ្ធផលដែលទទួលបានរួម និងឧបសគ្គនានាដែលអ្នកអនុវត្តផ្ទាល់បានជួបប្រទះ និងដាក់ចេញវិធានការអាទិភាពសម្រាប់ឆ្លើយតបឱ្យកាន់តែមានប្រសិទ្ធភាពឆ្ពោះទៅសម្រេចគោលដៅ៩៥ទី១ ដែល ពេលនេះប្រទេសកម្ពុជាទើបសម្រេចបាន។

តាមរយៈនៃការខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់ខ្ពស់របស់រដ្ឋាភិបាល ក្រោមកិច្ចដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ប្រទេសកម្ពុជាទទួលបានជោគជ័យក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដែលអត្រាផ្ទុកមេរោគអេដស៍ បានធ្លាក់ចុះជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំ។

**៥.២** តាមរយៈនៃកិច្ចប្រជុំនេះ ***លោកវេជ្ជបណ្ឌិត សំរិត សុវណ្ណរិទ្ធ*** អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ (NCHADS) បានបង្ហាញពីលទ្ធផលនៃការប៉ាន់ប្រមាណករណី ទាក់ទងមេរោគអេដស៍នៅឆ្នាំ២០២២ ដែលបានធ្វើការប៉ាន់ប្រមាណដោយក្រុមអ្នកបច្ចេកទេសនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងអង្គការ UNAIDS។ ដែលលទ្ធផលបានបង្ហាញដូចខាងក្រោម៖ នៅចុងឆ្នាំ២០២២ មនុស្សប្រមាណ ៧៦.០០០ (៦៣.០០០-៨៥.០០០) កំពុងផ្ទុកមេរោគអេដស៍ ហើយក្នុងនោះ ៧៤.០០០ (៦១.០០០-៨៣.០០០) ជាមនុស្សពេញវ័យដែលមានអាយុចាប់ពី១៥ឆ្នាំឡើងទៅ និងប្រហែល២.០០០ (១.៦០០-២.៤០០) កុមារ(០-១៤ឆ្នាំ)។ ៨៦% នៃអ្នកផ្ទុកមេរោគអេដស៍ទាំងអស់បានដឹងពីស្ថានភាពមេរោគអេដស៍របស់ពួកគេហើយបានប៉ាន់ស្មានថា មនុស្ស១១.០០០មិនដឹងថាពួកគេកំពុងផ្ទុកមេរោគអេដស៍នៅឡើយ។

**ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** បានធ្វើការបញ្ជាក់ថា៖ ការប៉ាន់ប្រមាណថា មានអ្នកឆ្លងមេរោគអេដស៍ ថ្មីចំនួន ១.៤០០ (១.២០០-១.៥០០) ក្នុងឆ្នាំ២០២២ ដែលមានន័យថាមនុស្សប្រហែល ៤នាក់ បានឆ្លងមេរោគអេដស៍ជារៀងរាល់ថ្ងៃ។ ការឆ្លងមេរោគអេដស៍ថ្មី ត្រូវបានកាត់បន្ថយចំនួន៩១% ចាប់តាំងពីការរីករាលដាលនៃមេរោគអេដស៍ខ្ពស់បំផុតក្នុងឆ្នាំ១៩៩៦ ប៉ុន្តែល្បឿននៃការធ្លាក់ចុះបាននិងកំពុងធ្លាក់ចុះ ហើយមានការថយចុះតែ៣៣% បើធៀបនឹងឆ្នាំ២០១០។ ការប៉ាន់ស្មានមេរោគអេដស៍ថ្មី ៥

បានបង្ហាញថា ការកើនឡើងសមាមាត្រនៃការឆ្លងមេរោគអេដស៍ថ្មី គឺស្ថិតក្នុងចំណោមបុរស និងក្មេងប្រុស ពួកគេមានចំនួន ៧៩% នៃការឆ្លងមេរោគអេដស៍ថ្មីទាំងអស់ក្នុងឆ្នាំ២០២២។ តាមចំនួនប្រជាជន ៨៣% នៃការឆ្លងមេរោគអេដស៍ថ្មីសរុបគឺស្ថិតក្នុងចំណោមប្រជាជនគន្លឹះ (បុគ្គលិកផ្នែកកម្សាន្តស្ត្រី បុរសរួមភេទជាមួយបុរស និងបុរសផ្សេងទៀតដែលរួមភេទជាមួយបុរស ស្ត្រីបំប្លែងភេទ អ្នកដែលប្រើ និងចាក់ថ្នាំញៀន និងដៃគូផ្លូវភេទរបស់ពួកគេ។ សមិទ្ធិផលរបស់ប្រទេសកម្ពុជាត្រូវបានចាត់ទុកជាគំរូ ក្នុងការសម្រេចបានខ្ពស់បំផុតនូវអត្រាទទួលសេវាព្យាបាល និងអត្រាកាត់បន្ថយមេរោគមកកម្រិតទាបបំផុតក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍។ គិតត្រឹមខែធ្នូ ឆ្នាំ២០២២ អ្នកផ្ទុកមេរោគអេដស៍ ៦៤.៩៣១នាក់ បាននឹងកំពុងទទួលបានការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ៩៩%នៃអ្នកផ្ទុកមេរោគអេដស៍ ដែលដឹងពីស្ថានភាពរបស់ពួកគេកំពុងទទួលបានការព្យាបាល និង៩៨%នៃអ្នកផ្ទុកមេរោគអេដស៍ លើការព្យាបាលត្រូវបានកាត់បន្ថយមេរោគមកកម្រិតទាបបំផុត។

**សេចក្តីសន្និដ្ឋាន៖**

- រក្សាបានជោគជ័យធៀបនឹងគោលដៅ 90-90-90 ។ អ្នកផ្ទុកមេរោគអេដស៍ដែលបានដឹងពីស្ថានភាពស្ទើរតែទាំងអស់បានទទួលការព្យាបាល ប៉ុន្តែត្រូវខិតខំបន្ថែមទៀត ដើម្បីសម្រេចគោលដៅ ៩៥ ទី១
- ការឆ្លងថ្មីនៃមេរោគអេដស៍ក្នុងចំណោមស្ត្រី មានការថយចុះគួរឱ្យកត់សម្គាល់ ប៉ុន្តែល្បឿននៃការថយចុះសរុបមិនទាន់លឿនគ្រប់គ្រាន់ទេ ហើយនិន្នាការនៃការឆ្លងថ្មីកើន ឡើងក្នុងចំណោមបុរសអាយុចាប់ពី ១៥ ឆ្នាំឡើង
- អត្រាឆ្លងថ្មីនៃមេរោគអេដស៍ មានកម្រិតខ្ពស់ ក្នុងចំណោមប្រជាជនវ័យក្មេង (15-24 years )
- ការដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍ អត្រាទទួលបានការព្យាបាល និងអត្រាបន្ទុកមេរោគអេដស៍ក្នុងឈាមត្រូវបានបង្ក្រាប (viral suppression) មានកម្រិតទាបក្នុងចំណោមកុមារ (ធៀបនឹងមនុស្សពេញវ័យ)
- ពុំទាន់បានសម្រេច គោលដៅលុបបំបាត់ការឆ្លងមេរោគអេដស៍ពីម្តាយទៅកូននៅឡើយ ទាមទារឱ្យកិច្ចខំប្រឹងប្រែង និងសហការរវាង NCHADS, NMCHC និងដៃគូអភិវឌ្ឍន៍លើកម្មវិធី PMTCT។

**មតិយោបល់៖**

-ទីចាត់ការសុខាភិបាលក្រសួងការពារជាតិ ស្នើសុំមានការធ្វើតេស្តរហ័សដល់ក្រុមប្រដាប់អាវុធ

-រាជធានីភ្នំពេញ មានសំណើគួរតែមានវគ្គបណ្តុះបណ្តាលដល់អ្នកគ្រប់គ្រងសិស្សដែលមានអាយុចាប់ពី១៥ ដល់២៤ឆ្នាំ ពីបញ្ហាអេដស៍ មូលហេតុសព្វថ្ងៃមានការឆ្លងច្រើនចំពោះក្រុមបុរសស្រលាញ់បុរសដែលមាន អាយុចាប់ពី ១៥ឆ្នាំ ទៅ២៤ឆ្នាំ។ ៤

នាឱកាសនោះ **ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការប្រធានអង្គប្រជុំបានបញ្ជាក់ថា នឹងទទួលយកសំណើនៅក្នុងកិច្ចប្រជុំដែលបានលើកឡើងនឹងពិភាក្សាជាមួយក្រុមការងារ ដោយយើងមិនអាចធ្វើបានគ្រប់គ្នាទេ យើងត្រូវជ្រើសរើសថាតើគួរធ្វើទៅលើក្រុមណាដែលងាយប្រឈម។ ឯកឧត្តម ក៏បានបន្តថា ជាក់ស្តែងប្រទេសកម្ពុជាយើង នៅមានឧបសគ្គក្នុងការសម្រេចឱ្យបាននូវគោលដៅ៩៥ ទី១ដែលនៅឆ្ងាយពីគោលដៅកំណត់ និងដែលទាមទារឱ្យយើងទាំងអស់គ្នាត្រូវបន្តរួមគ្នា រកវិធីសាស្ត្រប្រកបដោយប្រសិទ្ធភាពផ្សេងៗទៀត ដើម្បីសម្រេចគោលដៅនេះ។

ចុងបញ្ចប់ **ឯកឧត្តមបណ្ឌិត** ប្រធានអង្គប្រជុំបានបន្ថែមថា ការងារប្រយុទ្ធនឹងជំងឺអេដស៍ នៅមានរយៈពេលយូរទៅមុខទៀត ដែលតម្រូវឱ្យយើងបន្តធ្វើការរួមគ្នា រវាងអ្នកធ្វើគោលនយោបាយ និងយុទ្ធសាស្ត្រ អ្នកផ្តល់សេវា និងអ្នករងផលប៉ះពាល់។ ម្យ៉ាងទៀតត្រូវពង្រឹងភាពជាម្ចាស់ ចាំបាច់ត្រូវមានការផ្លាស់ប្តូរ ដើម្បីពិនិត្យលទ្ធភាពបង្កើនការផ្តល់ថវិកាជាតិ ដោយឡែកដល់ថ្នាក់ក្រោមជាតិដែលរួមមានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ឃុំ សង្កាត់ ដើម្បីបង្កើនបទអន្តរាគមន៍ឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ឱ្យចំលើការងារជាអាទិភាពពិសេសក្រុមប្រឈមមុខខ្ពស់ និងទីតាំងអាទិភាពដែលមានការចម្លងច្រើនដោយប្រើអន្តរាគមន៍ដែលមាន ប្រសិទ្ធភាពខ្ពស់ និងមានភាព ធន់នៃប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍៕

ថ្ងៃអង្គារ ១៣កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៣

**បានពិនិត្យត្រឹមត្រូវ**

**អ្នកធ្វើរបាយការណ៍**

**ជ.ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន**

**ប្រធានអង្គប្រជុំ**

**ស៊ុំ ផល្លា**

**បណ្ឌិត ឈឹម យិនដារ៉េត**